# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2014, 15:38
CMS/CFO: Sann Rada

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន** និង លោក **នួន ជា**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន និងមេធាវីការពារក្ដី លោក នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្ដឹងសាទុក្ខ

---

<u>ដាក់ដោយ៖</u>

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

**មេធាវីការពារក្ដីលោក នួន ជា**

មេធាវី សុន អរុណ

មេធាវី Victor KOPPE

<u>ដាក់ជូន៖</u>

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ ហើយបានប្រកាសថា លោក ខៀវ សំផន និង លោក នួន ជា មានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានផ្តន្ទាទោសពួកគាត់ ដាក់ពន្ធនាគារអស់មួយជីវិត[1]។ នៅថ្ងៃដដែលនោះ ភាគីនានាបានទទួលសេចក្តីជូនដំណឹងនៃសាលក្រមជាលាយលក្ខណ៍អក្សរជាបីភាសាការងាររបស់ អ.វ.ត.ក[2]។

២. មេធាវីការពារក្តីលោក ខៀវ សំផន និង មេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") ដែលមានបំណងប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ[3] ស្នើសុំពន្យារពេលកំណត់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ ព្រមទាំងស្នើសុំបង្កើនចំនួនទំព័រនៃឯកសារទាំងពីរនេះ ស្របតាមអត្ថបទច្បាប់ជាធរមាន។

## I. <u>ច្បាប់ដែលអនុវត្តចំពោះការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ</u>

៣. វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") ចែងថា៖
*"ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលបញ្ជាក់ពីមូលដ្ឋាននីមួយៗ ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់ ដែលនាំឲ្យសេចក្តីសម្រេចនោះមោឃៈ និងកំហុសអង្គហេតុ ដែលនាំឲ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខ ត្រូវដាក់សារណាបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ (...)"*។

---

[1] ប្រតិចារឹកសវនាការ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ **E1/241.1**។

[2] សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E313** ("សាលក្រម")។

[3] វិធាន ១០៤ និងវិធានបន្តបន្ទាប់ នៃវិធានផ្ទៃក្នុង។

៤. វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង ចែងអំពីពេលវេលាកំណត់៖
*"សេចក្តីសុំប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដូចមានកំណត់នៅក្នុង វិធាន ១០៥(៣) ត្រូវធ្វើក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬការជូនដំណឹងពីសាលក្រមនោះ តាមករណីសមស្រប។ ម្ចាស់បណ្តឹងសាទុក្ខ ត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខ ក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ"*។

៥. វិធាន ៣៩(១) នៃវិធានផ្ទៃក្នុងចែងថា គ្រប់ពេលវេលាកំណត់ទាំងអស់ដែលមានចែងក្នុងច្បាប់ជាធរមាន វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងសេចក្តីសម្រេចរបស់ចៅក្រម តាមករណីសមស្របណាមួយ ត្រូវតែគោរពតាមជាដាច់ខាត។ ទោះជាយ៉ាងណាក៏ដោយ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងបញ្ជាក់ថា អង្គជំនុំជម្រះអាចពន្យារពេលវេលាដែលខ្លួនបានកំណត់ តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន។

៦. មាត្រា ៨(៥) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត") ចែងអំពីការចាប់ផ្តើមរាប់ពេលវេលាកំណត់៖
*"លើកលែងតែមានការណែនាំផ្ទុយពីនេះរបស់សហចៅក្រមស៊ើបអង្កេត ឬពីអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក ពេលវេលាកំណត់ ត្រូវចាប់រាប់មួយថ្ងៃបន្ទាប់ពីថ្ងៃនៃការជូនដំណឹងពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក។ ក្នុងករណីពិសេស សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចសម្រេចថា ពេលវេលាកំណត់ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់នៃថ្ងៃដាក់ឯកសារជាបីភាសាផ្លូវការ"*។

៧. ភាសាប្រើប្រាស់ជាផ្លូវការក្នុងកិច្ចការរបស់ អ.វ.ត.ក គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង[4]។ មាត្រា ៧ នៃសេចក្តីណែនាំអនុវត្ត ចែងថា *"គ្រប់ឯកសារទាំងអស់ ត្រូវដាក់ជាភាសាខ្មែររួមជាមួយអង់គ្លេស និង/ឬបារាំង"*។

៨. អនុលោមតាមមាត្រា ៥(២) នៃសេចក្តីណែនាំអនុវត្ត ឯកសារដាក់នៅអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក *"មិនត្រូវលើសពី ៣០ ទំព័រជាភាសាអង់គ្លេស ឬបារាំង និង ៦០ ទំព័រជាភាសាខ្មែរ"*។

---

[4] មាត្រា ៤៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

មាត្រា ៥(៤) បញ្ជាក់ថា *"តាមការស្នើសុំរបស់ភាគីចូលរួម ចៅក្រមអាចបង្កើនចំនួនសន្លឹករបស់ឯកសារ នៅក្នុងកាលៈទេសៈពិសេស"*។

## II. <u>សារៈសំខាន់នៃសំណើនេះ</u>

៩. បណ្តឹងសាទុក្ខ ជាឧបាស្រ័យតែមួយគត់ប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ដោយហេតុថា *"សេចក្តីសម្រេចនៃអង្គជំនុំជម្រះតុលាការកំពូល គឺជាសេចក្តីសម្រេចចុងក្រោយ និងមិនត្រូវបង្វិលឲ្យអង្គជំនុំជម្រះសាលាដំបូងវិញឡើយ"*[5]។

១០. ប្រសិនបើដំណាក់កាលបណ្តឹងសាទុក្ខនឹងមាននីតិវិធីច្រើនជំហាន (សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ សារណាបណ្តឹងសាទុក្ខ[6] ចម្លើយតប និង/ឬ ការឆ្លើយតប[7] សវនាការលើបណ្តឹងសាទុក្ខ[8]) ជំហានទីមួយ (សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ) គឺជាជំហានសំខាន់បំផុត។

១១. ជាក់ស្តែង សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ត្រូវលើកឡើងពីមូលដ្ឋាននៃបណ្តឹងសាទុក្ខទាំងអស់ ទាំងខាងអង្គច្បាប់ និងអង្គហេតុ។ បន្ទាប់មកទៀត មូលដ្ឋាននៃបណ្តឹងសាទុក្ខដែលបានបង្ហាញ និងលើកឡើងទាំងនេះ នឹងត្រូវរៀបរាប់លម្អិត ក្នុងសារណាបណ្តឹងសាទុក្ខ *"ដោយបញ្ជាក់ពីឧទ្ធរណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែល<u>គាំទ្រ</u>មូលដ្ឋាននីមួយៗ"*[9]។

១២. ខុសពីតុលាការអន្តរជាតិផ្សេងទៀត[10] នៅ អ.វ.ត.ក គ្មានបទប្បញ្ញត្តិនៃអត្ថបទច្បាប់ជាធរមានណាមួយ ចែងអំពីការអនុញ្ញាតឲ្យកែប្រែមូលដ្ឋាននៃបណ្តឹងសាទុក្ខ ដែលបានលើកឡើងពីដំបូងនៅក្នុង

---

[5] វិធាន ១០៤(៣) នៃវិធានផ្ទៃក្នុង។

[6] វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

[7] មាត្រា ៨(៣) និងមាត្រា ៨(៤) នៃសេចក្តីណែនាំអនុវត្ត។

[8] វិធាន ១០៩ នៃវិធានផ្ទៃក្នុង។

[9] វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[10] មាត្រា ១០៨ នៃវិធាននីតិវិធី និងភស្តុតាង របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (TPIR) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (TPIY)។ វិធាន ៦១ នៃវិធានតុលាការព្រហ្មទណ្ឌអន្តរជាតិ (CPI)។ មាត្រា ១៧៧(គ) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ (TSL)។

សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ នោះទេ។

១៣. លើសពីនេះទៅទៀត វិធានផ្ទៃក្នុងចែងថា *"ភាគីមិនអាចលើកឡើងអំពីបញ្ហាណាមួយនៃអង្គហេតុ ឬអង្គច្បាប់ ដែលមិនបានសរសេរបង្ហាញមុន នៅក្នុងសារណានៃបណ្តឹងសាទុក្ខ នៅក្នុងអំឡុងពេលនៃសវនាការឡើយ"*[11]។

១៤. ជាពិសេស វិធានផ្ទៃក្នុងបញ្ជាក់យ៉ាងច្បាស់ថា *"វិសាលភាពនៃបណ្តឹងសាទុក្ខ ត្រូវកម្រិតត្រឹមបញ្ហាដែលលើកឡើងក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ"*[12]។

១៥. អាស្រ័យហេតុនេះ មូលដ្ឋាននៃបណ្តឹងសាទុក្ខ ដែលមិនត្រូវបានបង្ហាញ ឬលើកឡើង នៅដំណាក់កាលនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ នឹងមិនអាចត្រូវបានលើកឡើងនៅពេលក្រោយបានឡើយ ហើយអង្គជំនុំជម្រះតុលាការកំពូល ដែលជាស្ថាប័នសម្រេចសេចក្តីចុងក្រោយ ក៏នឹងមិនលើកយកមូលដ្ឋានថ្មីបែបនេះមកពិចារណាដែរ។ ដូច្នេះ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ត្រូវតែសរសេរបង្ហាញឲ្យបានសព្វជ្រុងជ្រោយ។

១៦. យើងឃើញហើយថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ គឺជាបញ្ហាប្រឈមដ៏ពិតប្រាកដមួយដែលជាយុត្តិកម្មសម្រាប់ឲ្យអង្គជំនុំជម្រះតុលាការកំពូលពន្យារពេលវេលាកំណត់ និងបង្កើនចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ព្រមទាំងពន្យារពេលវេលាកំណត់ និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ។ បញ្ហាប្រឈមនេះ មានទំហំធំធេងណាស់ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានប្រកាសទទួលស្គាល់ថា លោក ខៀវ សំផន និងលោក នួន ជា មានពិរុទ្ធភាពចំពោះអង្គហេតុទាំងមូល ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ និងបានផ្តន្ទាទោសពួកគាត់ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលជាទោសធ្ងន់បំផុត។

[11] វិធាន ១០៩(៦) នៃវិធានផ្ទៃក្នុង។

[12] វិធាន ១១០(១) នៃវិធានផ្ទៃក្នុង (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

## III. យុត្តិកម្មនៃការពន្យារពេលវេលាកំណត់ និងបង្កើនចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ

១៧. ច្បាស់ណាស់ថា ក្នុងករណីជាក់លាក់នៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមណាមួយ ពេលវេលាកំណត់ (៣០ ថ្ងៃ និង ៦០ ថ្ងៃ) និងចំនួនទំព័រ (៣០ ទំព័រ សម្រាប់ឯកសារនីមួយៗ) មិនគ្រប់គ្រាន់នោះទេ។

១៨. គួរកត់សម្គាល់ថា នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ម្ចាស់បណ្តឹងសាទុក្ខមានរយៈពេល ៣០ ថ្ងៃ[13] សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និង ៧៥ ថ្ងៃ[14] ឬ រហូតដល់ ៩០ ថ្ងៃ[15] សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខចំនួន ១០០ ទំព័រ[16] (ដោយមានលទ្ធភាពកែប្រែមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់ខ្លួនបាន)។ លើសពីនេះទៅទៀត ឯកសារទាំងនេះ អាចត្រូវបានដាក់តែមួយភាសាប៉ុណ្ណោះ។

១៩. សេចក្តីបញ្ជាក់ចុងក្រោយនេះ មានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះថានៅចំពោះមុខ អ.វ.ត.ក ការដាក់ជាចាំបាច់នូវឯកសារជាពីរភាសាផ្លូវការ ធ្វើឲ្យរឹតតែកាត់បន្ថយពេលវេលាកំណត់ថែមទៀត ដោយសារតែការបកប្រែ មុនពេលដាក់។ ជាក់ស្តែង[17] ឯកសារ ៣០ ទំព័រ សរសេរជាភាសាបារាំង ត្រូវការពេលប្រហែល ៦ ថ្ងៃធ្វើការ (មិនរាប់បញ្ចូលថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ដើម្បីបកប្រែជាភាសាមួយផ្សេងទៀត។ ចំណែកឯឯកសារ ១០០ ទំព័រ គឺត្រូវការពេល ២០ ថ្ងៃធ្វើការ (ស្មើនឹង ៤ សប្តាហ៍) ដើម្បីបកប្រែ។ ម្យ៉ាងវិញទៀត យើងខ្ញុំសូមគូសបញ្ជាក់ថា ភាពស្មុគស្មាញនៃការងារតាក់តែងសារណាបណ្តឹងសាទុក្ខ នាំឲ្យមានការកែប្រែ បន្ថែមបន្ថយ រហូតដល់ផុតពេលវេលា

---

[13] មាត្រា ១០៨ នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់ TPIR និង TPIY, វិធាន ១៥០ នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់ CPI, មាត្រា ១៧៧(ក) នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់ TSL។

[14] មាត្រា ១១១ នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់ TPIR និង TPIY,មាត្រា ១៨២(ក) នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់ TSL។

[15] វិធាន ៥៨ នៃវិធានតុលាការ CPI។

[16] វិធាន ៥៨ នៃវិធានតុលាការ CPI, គ)១.ក) នៃសេចក្តីណែនាំអនុវត្តស្តីពីចំនួនទំព័រនៃសារណា និងបណ្តឹងសាទុក្ខ (TPIR), I.គ)១.ក) នៃសេចក្តីណែនាំអនុវត្តស្តីពីចំនួនទំព័រនៃសារណា និងបណ្តឹងសាទុក្ខ (TPIY), មាត្រា ៥(១) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ TSL (នៅ TPIR, TPIY និង TSL កម្រិតត្រឹម ៣០ ០០០ ពាក្យ ស្មើនឹងប្រហែល ១០០ ទំព័រ)។

[17] ផ្អែកលើចំនួនទំព័របកប្រែ ៥ ទំព័រ ជាមធ្យមក្នុងមួយថ្ងៃ នៅពេលដែលអង្គភាពបកប្រែភាសាពុំមានឯកសារបកប្រែច្រើន។

កំណត់ ដែលមិនអាចឲ្យដាក់ឲ្យបកប្រែបណ្តឹង សរសេរបណ្តឹងនោះទេ។

២០. អាស្រ័យហេតុនេះ បើទោះបីជាមិនដឹងអំពីទឡ្ហីករណ៍ ដែលអាចត្រូវបានទាញចេញពីលក្ខណៈពិសេសនៃការកាត់ចេញនូវពេលវេលាបកប្រែ ដូចបានលើកឡើងខាងលើ នៅចំពោះមុខ អ.វ.ត.ក ក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការអន្តរជាតិ អនុញ្ញាតឲ្យពន្យារពេលកំណត់ និង បង្កើនចំនួនទំព័រនៃសេចក្តីសន្និដ្ឋាន ដោយពិនិត្យទៅលើកាលៈទេសៈដោយឡែកនៃរឿងក្តីនីមួយៗ ប្រសិនបើខ្លួនយល់ឃើញថា វាជាផលប្រយោជន៍យុត្តិធម៌ ក្នុងការធានាថា ម្ចាស់បណ្តឹងសាទុក្ខ មានពេលវេលាគ្រប់គ្រាន់ ដើម្បីសរសេរ *"សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ"*[18] និង/ឬ *"សារណាបណ្តឹងសាទុក្ខ"*[19] ប្រកបដោយអត្ថន័យខ្លឹមសារ។

២១. រឿងក្តីលោក ខៀវ សំផន ដូចគ្នានឹងករណីនេះដែរ ដោយសារតែទំហំធំធេង និងភាពស្មុគស្មាញនៃសំណុំរឿង (សក្ខីកម្ម ឯកសារភ័ស្តុតាង សេចក្តីសម្រេចនានា ក្នុងចំនួនដ៏ច្រើន...)[20] ភាពវែង និងភាពស្មុគស្មាញនៃសាលក្រម[21] និង/ឬប្រភេទ និងវិសាលភាពនៃមូលដ្ឋានបណ្តឹងសាទុក្ខ[22]។ យ៉ាង

---

[18] *រដ្ឋអាជ្ញា* តទល់នឹង *Stanisic* និង *Zupljanin*, IT-08-91-A, សេចក្តីសម្រេចលើសំណើរួមរបស់មេធាវីការពារក្តីសុំពន្យារពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេច *Stanisic* និង *Zupljanin* ចុះខែ មេសា ឆ្នាំ ២០១៣") ទំព័រ ២។ *រដ្ឋអាជ្ញា* តទល់នឹង *Dordevic*, IT-05-87/1-A, សេចក្តីសម្រេចលើសំណើរបស់ Vlastimir Dordevic សុំពន្យារពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ("សេចក្តីសម្រេច *Dordevic*") ទំព័រ ២។

[19] *រដ្ឋអាជ្ញា* តទល់នឹង *Stanisic* និង *Simatovic*, IT-03-69-A, សេចក្តីសម្រេចលើសំណើបន្ទាន់របស់ Stanisic សុំបន្ថែមចំនួនពាក្យ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ("សេចក្តីសម្រេច *Stanisic* និង *Simatovic*") ទំព័រ ៣, *រដ្ឋអាជ្ញា* តទល់នឹង *Stanisic* និង *Zupljanin*, IT-08-91-A, សេចក្តីសម្រេចលើសំណើរបស់ Mico Stanisic និង Stojan Zupljanin សុំកែប្រែពេលវេលា និងចំនួនពាក្យសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ ("សេចក្តីសម្រេច *Stanisic* និង *Zupljanin* ចុះខែ មិថុនា ឆ្នាំ ២០១៣") ទំព័រ ២ និង ៤, *រដ្ឋអាជ្ញា* តទល់នឹង *Tolimir*, IT-05-88/2-A, សេចក្តីសម្រេចលើសំណើសុំកំណត់ពេលវេលាសម្រាប់ការដាក់សារណារបស់ម្ចាស់បណ្តឹងសាទុក្ខ និងបន្ថែមចំនួនពាក្យ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ("សេចក្តីសម្រេច *Tolimir*") ទំព័រ ៣, *រដ្ឋអាជ្ញា* តទល់នឹង *Dordevic*, IT-05-87/1-A, សាលក្រម ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ ឧបសម្ព័ន្ធ ក៖ ប្រវត្តិនីតិវិធី កថាខណ្ឌ ៣ ទំព័រ ៤១៤។

[20] *Karemera* និង *Ngirumpatse* តទល់នឹងរដ្ឋអាជ្ញា, ICTR-98-44-A, សេចក្តីសម្រេចលើសំណើសុំពន្យារពេលដាក់បណ្តឹងសាទុក្ខ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សេចក្តីសម្រេច Karemera") កថាខណ្ឌ ៩។

[21] សេចក្តីសម្រេច *Stanisic* និង *Simatovic* ទំព័រ ៣, សេចក្តីសម្រេច *Stanisic* និង *Zupljanin* ចុះខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ

ណាមិញ ក្នុងរឿងក្តី *Lubanga* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ យល់ឃើញថា *"ដោយសារតែវាជាឧបាស្រ័យទីមួយប្រឆាំងនឹងសាលក្រមមួយ (...) ដែលអាចលើកបញ្ហាថ្មី និងស្មុគស្មាញ និងដោយសារតែសាលក្រមវែង មានកាលៈទេសៈពិសេស (...) ជាយុត្តិកម្មសម្រាប់ការបង្កើនចំនួនទំព័រដែលអនុញ្ញាត សម្រាប់សារណាបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga"*[23]។

២២. នៅចំពោះមុខ អ.វ.ត.ក យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល មិនសូវសម្បូរបែបនោះទេ។ ជាក់ស្តែង មកទល់នឹងពេលនេះ ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល បានទទួលបណ្តឹងសាទុក្ខតែមួយគត់ប្រឆាំងនឹងសាលក្រម (ក្នុងរឿងក្តី **ឌុច**) និងបណ្តឹងសាទុក្ខភ្លាមៗតិចតួចបំផុត (ក្នុងសំណុំរឿង ០០២/០១)។ សំណុំរឿង ០០២/០១ ជារឿងក្តីទីពីរដែលត្រូវជំនុំជម្រះ ហើយយន្តការនៃបណ្តឹងបន្ទាន់បង្ខំមិនមានចែងនៅ អ.វ.ត.ក នោះទេ (មានតែមូលហេតុបួនប៉ុណ្ណោះដែលបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ[24])។

២៣. ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូល ធ្លាប់បានពន្យារពេលវេលាកំណត់ ដែលចែងដោយអត្ថបទច្បាប់រួចមកហើយ។ ក្នុងសំណុំរឿង ០០២/០១ ក្រោយពីទទួលបានបណ្តឹងសាទុក្ខភ្លាមៗ អង្គជំនុំជម្រះតុលាការកំពូល បានពន្យារពេលវេលាកំណត់ ដោយសារតែភាពស្មុគស្មាញនៃបញ្ហាអង្គហេតុ និងអង្គច្បាប់ ដែលបានលើកឡើង[25] ឬក៏ដោយសារតែ *"ទំហំធំធេង ភាពស្មុគស្មាញ និង*

---

២ និង ៤, សេចក្តីសម្រេច *Tolimir* ទំព័រ ៣ និង ៤, សេចក្តីសម្រេច *Stanisic* និង *Zupljanin* ចុះខែ មេសា ឆ្នាំ ២០១៣ ទំព័រ ២-៣, សេចក្តីសម្រេច *Karemera* កថាខណ្ឌ ៩, សេចក្តីសម្រេច *Dordevic* ទំព័រ ២។

[22] សេចក្តីសម្រេច *Stanisic* និង *Simatovic* ទំព័រ ៣។

[23] *រដ្ឋអាជ្ញា* តទល់នឹង *Lubanga*, ICC-01/04-01/06 A5, សេចក្តីសម្រេចលើសំណើរបស់ Thomas Lubanga សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៥។ គួរបញ្ជាក់ថា ការបន្ថែមចំនួនទំព័រត្រូវបានអនុញ្ញាតចំពោះសារណាបណ្តឹងសាទុក្ខដែលពាក់ព័ន្ធនឹងការប្រកាសពិរុទ្ធភាពតែប៉ុណ្ណោះ។ សារណាដោយឡែកត្រូវបានដាក់ ស្តីពីទោស ព្រមទាំងសំណងដល់ជនរងគ្រោះ។

[24] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

[25] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេល ដើម្បីធ្វើសារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា តាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E116/1/2/1** កថាខណ្ឌ ៦។

*សារៈសំខាន់នៃបញ្ហាដែលបានលើកឡើង"*[26]។ ឧទាហរណ៍ នៅក្នុងរឿងក្តី **ឌុច** អង្គជំនុំជម្រះតុលាការកំពូល បានផ្តល់ពេលវេលាបន្ថែម ៣០ ថ្ងៃ ដល់មេធាវីការពារក្តី សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ ដោយសារតែទំហំធំធេង ភាពស្មុគស្មាញនៃសំណុំរឿង និងចំនួនដ៏ច្រើននៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង *"ដែលថ្មីៗហើយប្លែកជាច្រើន ទៅលើអង្គហេតុ និងអង្គច្បាប់"* ព្រមទាំងដោយសារតែ *"ភាពថ្មីហើយប្លែកនៃសំណុំរឿង"* ក៏ដូចជាដោយសារតែការតែងតាំងថ្មីនូវមេធាវីការពារក្តីមួយរូបទៀត[27]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូល ក៏បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញារៀបរាប់លម្អិតនូវមូលដ្ឋានបីនៃបណ្តឹងសាទុក្ខ ក្នុងសារណាចំនួន ៦៥ ទំព័រ ជាភាសាអង់គ្លេស[28]។

២៤. វាមិនមែនឥតប្រយោជន៍នោះទេ ក្នុងការរំឭកថា ក្នុងរឿងក្តី **ឌុច** សហព្រះរាជអាជ្ញា បានលើកឡើងនូវមូលដ្ឋានបីនៃបណ្តឹងសាទុក្ខ (ការកំណត់ទោស ការបូកទំនួលខុសត្រូវ និងឧក្រិដ្ឋកម្មនៃការធ្វើឲ្យក្លាយជាទាសករ)[29] ខណៈដែលមេធាវីការពារក្តី បានលើកឡើងនូវមូលដ្ឋាននៃបណ្តឹងសាទុក្ខតែពីរប៉ុណ្ណោះ (យុត្តាធិការលើរូបបុគ្គល និងការកំណត់ទោស)[30]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល មិនទាន់បានសម្រេចលើបញ្ហាណាមួយផ្សេងទៀត ដែលប្រហែលជានឹងដាក់ជូន ក្នុងសំណុំរឿង ០០២/០១ នៅឡើយទេ។

---

[26] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ឯកសារ **E163/5/1/2/1** ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៧។

[27] រឿងក្តី ឌុច "សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច សុំពន្យារកាលបរិច្ឆេទសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារ **F6/2** កថាខណ្ឌ ៨ និងកថាខណ្ឌ ១០។

[28] រឿងក្តី ឌុច សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារ **F5/2** កថាខណ្ឌ ៥-៨។

[29] រឿងក្តី ឌុច បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារ **F10** (សំណៅបកប្រែសារណានេះជាភាសាបារាំងមានដល់ទៅ ៧៥ ទំព័រ)។

[30] រឿងក្តី ឌុច សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ **F14**។

២៥. ក៏ប៉ុន្តែ ដោយសារតែ អ.វ.ត.ក ជំនុំជម្រះលើអង្គហេតុ ដែលបានកើតឡើង នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយអង្គជំនុំជម្រះតុលាការកំពូល មិនទាន់បានសម្រេចលើបញ្ហាយុត្តាធិការ ក៏ដូច ជាលើការកំណត់សម័យកាលនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ ក្នុងសំណុំរឿង ០០២/០១ ព្រមទាំងលើគោលការណ៍នៃភាពអាចទទួលយកបាន និងវាយតម្លៃភ័ស្តុតាង ក្នុងប្រព័ន្ធច្បាប់ចម្រុះ វាមិនមានអ្វីសង្ស័យទេថា បញ្ហាស្មុគស្មាញជាច្រើននឹងត្រូវលើកឡើងជាលើកដំបូង នៅពេលធ្វើ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤[31]។ តាមពិត បញ្ហា គតិយុត្តិ និងការចោទប្រកាន់ផ្នែកអង្គហេតុជាច្រើននៃសំណុំរឿង ០០២/០១ មិនអាចប្រៀបធៀប បានជាមួយនឹងបញ្ហាគតិយុត្តិ និងការចោទប្រកាន់ផ្នែកអង្គហេតុនៃរឿងក្តី **ឌុច** នោះទេ។

២៦. ដូចគ្នាផងដែរ ការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បានធ្វើឱ្យលេចឡើងនូវបញ្ហាថ្មី និងស្មុគស្មាញជាច្រើន ជាពិសេស ពាក់ព័ន្ធនឹងភាពអាចបំបែកបាននៃរឿងក្តី និងសេចក្តីសន្និដ្ឋាន ដែលកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល[32]។

២៧. ក្រៅពីនេះទៀត ដោយសារតែសាលក្រមវែង (៧៧៧ ទំព័រ ជាភាសាបារាំង ៦២៣ ទំព័រ ជាភាសា អង់គ្លេស ៩៨១ ទំព័រ ជាភាសាខ្មែរ ដោយមិនគិតពីឧបសម្ព័ន្ធ ជាមួយនឹងកំណត់សម្គាល់ជើងទំព័រ ៣២៩៨) និងទំហំធំធេងនៃសំណុំរឿង (សក្ខីកម្ម ៩២[33] សវនាការ ២៣៧ ថ្ងៃ[34] ឯកសារភ័ស្តុតាង ៥៨២៤[35] សេចក្តីសម្រេចមុនចេញសាលក្រម ជាង ២៥០[36]) ពេលវេលាកំណត់ដែលចែងដោយ

---

[31] ជាអាទិ៍ ដោយសារតែពុំមានយន្តការនៃការបណ្តឹងបន្ទាន់បន្ទំ។ ឧទាហរណ៍ សូមមើល៖ យោបល់ជំទាស់របស់ចៅក្រម KLONOWIECKA-MILART និងចៅក្រម JAYASINGHE ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **E51/15/1/2.1** កថាខណ្ឌ ៥។

[32] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការ បំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ **E301/9/1/1/3** កថាខណ្ឌ ៧៧-៨៥។

[33] សាលក្រម កថាខណ្ឌ ៣២។

[34] រហូតដល់ថ្ងៃចុងក្រោយនៃការធ្វើសេចក្តីបញ្ចប់ការពិភាក្សាដេញដោល ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **E1/237.1**។

[35] សាលក្រម កថាខណ្ឌ ៣៣។

[36] ប្រតិចារឹកសវនាការ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ **E1/237.1** ទំព័រ ៥៦ បន្ទាត់ ១៦-១៨ ប្រហែលម៉ោង [14.12.47]។

អត្ថបទច្បាប់ នឹងមិនអាចឲ្យរៀបចំសារណាបណ្តឹងសាទុក្ខ ប្រកបដោយគុណភាព និង *"អត្ថន័យខ្លឹមសារ"* បាននោះទេ។

២៨. ក្នុងបរិបទនេះ វាពិតជាមានកាលៈទេសៈពិសេស និងសំអាងហេតុអាចយកជាការបាន សម្រាប់ជាយុត្តិកម្មនៃការពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រដែលអនុញ្ញាត។

២៩. មេធាវីការពារក្តី ដឹងយ៉ាងច្បាស់ថា *"គុណភាព និងប្រសិទ្ធភាពនៃសារណាបណ្តឹងសាទុក្ខ មិនមែនអាស្រ័យលើប្រវែងនោះទេ គឺវាអាស្រ័យលើភាពច្បាស់លាស់ និងភាពរឹងមាំនៃទឡ្ហីករណ៍"*[37]។

៣០. ដោយសារតែឧបសគ្គខាងបកប្រែ សារៈសំខាន់នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ (សូមមើលផ្នែកទី ២ ខាងលើ) ទំហំធំធេង និងភាពស្មុគស្មាញនៃសាលក្រមនិងសំណុំរឿង មេធាវីការពារក្តី យល់ឃើញថាជាការសមហេតុផលក្នុងការផ្តល់ជូនខ្លួននូវ៖

- ពេលវេលា ៧៤ ថ្ងៃ សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចំនួន ៥០ ទំព័រ ជាភាសាបារាំង ឬជាភាសាអង់គ្លេស និងសមមូលតាមការតម្រូវជាភាសាខ្មែរ (១៤ ថ្ងៃ ចាំបាច់សម្រាប់ការបកប្រែ)[38] ហើយគិតចាប់ពីរយៈពេលនេះ នូវ

- ពេលវេលា ១១៧ ថ្ងៃ សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ ចំនួន ១៥០ ទំព័រ ជាភាសាបារាំង ឬជាភាសាអង់គ្លេស និងសមមូលតាមការតម្រូវជាភាសាខ្មែរ (៤២ ថ្ងៃ ចាំបាច់សម្រាប់ការបកប្រែ)[39]។

---

[37] សេចក្តីសម្រេច *Stanisic* និង *Simatovic* ទំព័រ ២។

[38] សម្រាប់ការបកប្រែឯកសារ ៥០ ទំព័រ ជាភាសាខ្មែរ គេត្រូវការរយៈពេលប្រហែល ១០ ថ្ងៃធ្វើការ ស្មើនឹង ២ សប្តាហ៍គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។

[39] សម្រាប់ការបកប្រែឯកសារ ១៥០ ទំព័រ ជាភាសាខ្មែរ គេត្រូវការរយៈពេលប្រហែល ៣០ ថ្ងៃធ្វើការ ស្មើនឹង ៦ សប្តាហ៍គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។

## អាស្រ័យហេតុនេះ

៣១. មេធាវីការពារក្តី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

- **អនុញ្ញាត** ឲ្យមេធាវីការពារក្តីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចំនួន ៥0 ទំព័រ ជាភាសាបារាំង ឬជាភាសាអង់គ្លេស និងសមមូលតាមការតម្រូវជាភាសាខ្មែរ ក្នុងរយៈពេល ៧៤ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រម ជាបីភាសា។

- **អនុញ្ញាត** ឲ្យមេធាវីការពារក្តីដាក់សារណាបណ្តឹងសាទុក្ខ ចំនួន ១៥0 ទំព័រ ជាភាសាបារាំង ឬជាភាសាអង់គ្លេស និងសមមូលតាមការតម្រូវជាភាសាខ្មែរ ក្នុងរយៈពេល ១១៧ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN | រាជធានីភ្នំពេញ<br><br>រាជធានីភ្នំពេញ<br><br>រាជធានីភ្នំពេញ | |
| | មេធាវី សុន អរុណ<br><br>មេធាវី Victor KOPPE | រាជធានីភ្នំពេញ<br><br>រាជធានីភ្នំពេញ | |